KPI 0496

# សម្ភាសន៍ជាមួយឈ្មោះ ហង់ អឿន ភេទប្រុស អាយុ៦៦ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហម «ទាហាន»

## សព្វថ្ងៃរស់នៅភូមិដំណាក់ឈើក្រុំ ឃុំស្នាយអញ្ជិត ស្រុកជុំគិរី ខេត្តកំពត

## ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០០:២៣:៥៨

## ១២ទំព័រ

ដានី : អ៊ំ ជំបូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ តើអ៊ំឈ្មោះ អីដែរ?

អឿន : ឈ្មោះ ហង់ អឿន។

ដានី : ហង់ អឿន អេះ! អ៊ំ អាយុប៉ុន្មានហើយសព្វថ្ងៃ?

អឿន : ៦៦ឆ្នាំ ។

ដានីៈ ៦៦ អេះ?

អឿនៈ បាទ ។

ដានី : អ៊ំសព្វថ្ងៃរស់នៅ ភូមិ ឃុំ ស្រុក អីដែរ?

អឿន : អើក្នុងភូមិដំណាក់ឈើក្រុម ស្រុកជុំគិរី ខេត្តកំពត ។

ដានី : ឃុំអីហ្នឹង?

អឿន : ឃុំស្នាយអញ្ជិត ។

ដានី : ស្នាយអញ្ជិត?

អឿន : បាទៗ

ដានី : ខេត្តកំពត ជុំគិរី ខេត្តកំពត?

អឿន : បាទ!

ដានី : ស្រុកកំណើតកើតជា អ៊ំ នៅណាដែរ?

អឿន : ខ្ញុំនៅហ្នឹងដែរ ។

ដានី : នៅណា នៅហ្នឹងភូមិហ្នឹងដែរ?

អឿន : បាទ ។

ដានី : ប៉ុន្តែពីដើមមកហ្នឹងស្រុកជុំគិរីដែរឬមិនមែនទេ?

អឿន ៖ បាទ!ស្រុកឈូកពីរដើម ។

ដានី ៖ ប្រពន្ធ អ៊ំ គាត់ ឈ្មោះអីដែរ?

អឿន ៖ ឈ្មោះ ឥឡូវហ្នឹង ។

ដានី ៖ អ៊ំ មានប្រពន្ធពីរមានទេ?

អឿន ៖ បាទ ។

ដានី ៖ បាទ! ចុះ ប្រពន្ធ អ៊ំ សព្វថ្ងៃឈ្មោះ អី ដែរ?

អឿន ៖ ឈ្មោះ ញាញ់ ណាង ប្រពន្ធគាត់ឈ្មោះ ញាញ់ ណាង ។

ដានី ៖ ឈ្មោះអីគេ?

អឿន ៖ ញាញ់ ណាង ។

ដានី ៖ គាត់អាយុប៉ុន្មានហើយ?

អឿន ៖ អើ៥៦អីហ៊ិនហ្នឹង(ស្តាប់មិនច្បាស់ មានខ្យល់ខ្លាំង) ។

ដានី ៖ អ៊ំមានកូនចៅទាំងអស់ប៉ុន្មាននាក់?

អឿន ៖ ខ្ញុំមាន៥នាក់ ។

ដានី ៖ ៥នាក់! ចុះអ៊ំ គ្រួសារ អ៊ំ មុនឈ្មោះ អី ដែរ?

អឿន ៖ គ្រួសារខ្ញុំមុនឈ្មោះ អីហើយទេ ភ្លេចអស់ ឈ្មោះអើ ដាក់ រិន ។

ដានី ៖ ឈ្មោះ រិន ចុះ អ៊ំមានកូនចៅទេ?

អឿន ៖ កូនអត់មានផង ។

ដានី ៖ អត់មានទេ?

អឿន ៖ បាទ!ស្លាប់អស់ហើយ ។

ដានី ៖ ចុះ គាត់ប្រពន្ធ អ៊ំ មុន?

អឿន ៖ ហ្នឹងហើយស្លាប់អស់ហើយ ។

ដានី ៖ ស្លាប់!ស្លាប់ពីអង្កាល់ដែរ?

អឿន ៖ ស្លាប់យូរហើយតាំងពីជំនាន់រត់ ។

ដានី ៖ រត់!រត់៧៩ហ្នឹង?

អឿន ៖ បាទ ។

ដានី ៖ ស្លាប់ដោយសារមូហេតុអ៊ីទៅ?

អឿន ៖ ស្លាប់កាលហ្នឹងបែកអាពតភ្លាម ខ្ញុំធ្វើកងទ័ពចុះ!

ដានី ៖ អត់ដឹងថាស្លាប់មូលហេតុអីទេ?

អឿន ៖ អត់!ប៉ុនលឺគេថាដូចថាអើយួនបាញ់បាក់ភ្លៅ ហើយវាទៅតាមកងចល័ត ហ្នឹងចូលលួចដំឡូងគេណា!ដល់យួនវាទាន់វាឃើញបាញ់បាក់ភ្លៅទៅ ហើយគេថាយួនសម្លាប់ មិនដឹងយ៉ាងម៉េចទេ ខ្ញុំអត់ដឹងដែរ ស្រាវជ្រាវវាអត់ដឹងដែរ ពូណា ។

ដានី ៖ កូនប៉ុន្មាននាក់?

អឿន ៖ កូនមួយ ។ កូនមួយហ្នឹងក៏ស្លាប់ដែរអត់ឃើញ កាលហ្នឹងកូនតូចណាពូកាលហ្នឹងបែកគ្នាទាន់ ។

ដានី ៖ កូនស្រីឬកូនប្រុស?

អឿន ៖ កូនស្រី ។

ដានី ៖ ចុះកូនអ៊ំរាល់ថ្ងៃមាន៥នាក់ទៀត?

អឿន ៖ បាទ!មាន៥នាក់ទៀត ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អឿន ៖ ស្រី២ ប្រុស៣ ។

ដានី ៖ អ៊ំ ការក្រោយឆ្នាំណាដែរ?

អឿន ៖ មកពីរត់វិញ ។

ដានី ៖ ការជាមួយគាត់ឆ្នាំណា?

អឿន ៖ កាលចុះមកពីរត់ ពូ ។

ដានី ៖ ឆ្នាំណាចុះមកពីរត់?

អឿន ៖ ពីរឆ្នាំប៉ុន្មានទេកាលហ្នឹង កាលឆ្នាំមកពីរត់ឆ្នាំ៨០ បាទៗ ។

ប្រពន្ធ៖ ការឆ្នាំមកពីរត់ឆ្នាំ៧៩ អើឆ្នាំ៨០ "អ្នកអង្គុយជិតនិយាយជំនួស" ។

ដានី ៖ ចុះអ៊ំ សព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

អឿន ៖ ខ្ញុំអត់ធ្វើអីទេធ្វើស្រែ ។

ដានី ៖ ធ្វើតែស្រែ?

អឿន ៖ បាទ ។

ដានី ៖ ចុះឪពុកអ៊ំ ឈ្មោះអីទៅ?

អឿន ៖ ឈ្មោះ ណុប ។

ដានី ៖ ឪពុកឈ្មោះអី ណុប?

អឿន ៖ “អ្នកជិតខាងនិយាយជំនួស” ថា ឈ្មោះ ហង់ ណុប ។

ដានី ៖ ឈ្មោះ អី ណុប?

អឿន ៖ មិនដឹងឈ្មោះអី ណុប ដែរបើ ជីតាគាត់មិនដឹងឈ្មោះ អីដែរ បើឪពុកគាត់ឈ្មោះ ហង់ ។

ដានី ៖ គាត់ស្លាប់ពីអង្កាល?

អឿន ៖ ស្លាប់តាំងពីឆ្នាំ៧៥ - ៧៦ ។

ដានី ៖ ចុះម្តាយ?

អឿន ៖ ម្តាយក៏ស្លាប់កាលហ្នឹងដែរ ។

ដានី ៖ ឈ្មោះ អីដែរ?

អឿន ៖ ប៉ិច អ៊ីវ ។

ដានី ៖ ចុះអ៊ំមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

អឿន ៖ បងប្អូនខ្ញុំនៅមុនអើយទាំងអស់១០នាក់ជាងតែស្លាប់អស់នៅសល់៥នាក់ ក្រោយពីហ្នឹងស្លាប់អស់ហើយ ។

ដានី ៖ អញ្ចឹងអើប៉ុន្មាននាក់១០ប៉ុន្មាននាក់ទាំងអស់?

អឿន ៖ ទាំងអស់១០ប៉ុន្មានហើយទេ មើ៦នាក់ស្រី៣នាក់ស្លាប់អស់ នៅសល់ប្រុស២នាក់ ស្រី៣នាក់ ។

ដានី ៖ អ៊ំ កូនទីប៉ុន្មានហើយ?

អឿន ៖ ខ្ញុំកូនបន្ទាប់ពៅ ។

ដានី ៖ កូនបន្ទាប់ពៅ?

អឿន ៖ បាទ ។

ដានី ៖ កូនទីប៉ុន្មានហើយបន្ទាប់ពៅ?

អឿន ៖ កូនទី៧ ។

ដានី ៖ បាទ! ចុះអ៊ំកាលពីក្មេងៗ អ៊ំ បានរៀនសូត្រអី ដល់ថ្នាក់ណាដែរ?

អឿន ៖ រៀនសូត្រថ្នាក់កាលពី១២កាលជំនាន់ចាស់ ។

ដានី ៖ រៀនសូត្របានមួយឆ្នាំទេ អញ្ចឹង?

អឿន ៖ បាទ!បានមួយឆ្នាំ ។

ដានី ៖ រៀននៅសាលាណាទៅ?

អឿន៖ នៅវត្តហ្នឹង ។

ដានី ៖ វត្តហ្នឹងវត្តអីទេ?

អឿន ៖ រៀននៅតែវត្តទេ?

ដានី ៖ វត្តអីទៅ?

អឿន ៖ វត្តថ្មីៗ

ដានី ៖ ក្នុងភូមិ?

អឿន ៖ ភូមិដំណាក់ឈើក្រមៗ

ដានី ៖ ចុះអ៊ំ ដល់ពេលរៀនបានមួយឆ្នាំហើយយ៉ាងម៉េចទៀតទៅ?

អឿន ៖ ខ្ញុំរៀនហើយបានមួយឆ្នាំអញ្ចឹងខ្ញុំនៅតែនឹងវត្តទេ ខ្ញុំនៅធ្វើក្មេងលោកកាលនៅរៀនធម៌បួស ដល់រៀនចឹងទៅ នៅវត្តយូរៗចឹងទៅក៏កើតសង្គ្រាម កើតសង្គ្រាមចឹងទៅកាលជំនាន់ហ្នឹងគេប្រមូលកងទ័ពចូលកងទ័ពទៅបាទអត់បានបួសអីលីងបាទៗ

ដានី ៖ អញ្ចឹង អ៊ំ រៀនបានថ្នាក់ទី១២ហើយមកធ្វើកូនសិស្សលោក?

អឿន ៖ បាទៗ

ដានី ៖ ធ្វើកូនសិស្សលោកពីឆ្នាំណា ដល់ឆ្នាំណាដែរបាទ?

អឿន ៖ ពីឆ្នាំ៥៨-៧០ចេញទៅកងទ័ពៗ

ដានី ៖ ឆ្នាំ៧០ចេញទៅកងទ័ព?

អឿន ៖ បាទៗ

ដានី ៖ អញ្ចឹងនៅលើវត្តតាំងពីឆ្នាំណាដែររហូតដល់ឆ្នាំ៧០?

អឿន ៖ នៅតាំងពី៦៣កកើតវត្តហ្នឹងមកៗ

ដានី ៖ នៅ៧ឆ្នាំអញ្ចឹង?

អឿន ៖ បាទៗ

ដានី ៖ តែអ៊ំអត់បានបួសលោកទេ?

អឿន ៖ អត់បានបួសៗ

ដានី ៖ ដល់ពេលឆ្នាំ៧០ម៉េចបានជាអ៊ំចេញទៅធ្វើកងទ័ព?

អឿន ៖ កាលហ្នឹងគេប្រមូលកម្លាំងតស៊ូហើយចេះតែទៅអញ្ចឹងទៅ ទៅមួយគេហ្នឹងឯងអញ្ចឹងទៅៗ

ដានី ៖ ទៅជាមួយពីណាខ្លះទៅកាលហ្នឹង?

អឿន ៖ មើលទៅគ្នាច្រើន ទៅតាមរយៈអប់រំរបស់អើមេទ័ពគេហ្នឹងកាលហ្នឹងជំនាន់អើ តា កងចាប តាប៊ិត គាត់បំផុសបំផុលៗ

ដានី ៖ គាត់មកតាកងចាប តាប៊ិត ហ្នឹងគាត់មកបំផុសបំផុលនៅណាដែរ?

អឿន ៖ មកម្តុំហ្នឹង ។

ដានី ៖ មកម្តុំហ្នឹង?

អឿន ៖ បាទ ។

ដានី ៖ ពីឆ្នាំណាដែរគាត់មក?

អឿន ៖ កាលហ្នឹងតាំងពីឆ្នាំ៧០ ណោះពូ ។

ដានី ៖ កាលណោះគាត់មកបំផុសបំផុលអីថាម៉េចខ្លះទៅ តាម អ៊ំ នៅចាំ?

អឿន ៖ គាត់អើលើកអំពីបញ្ហាអើជិះជាន់របបនាយទន់ បាទ បៀតបៀនសិទ្ធសេរីភាព ។ កាលជិនាន់ហ្នឹង ការអប់រំរបស់ថ្នាក់ដឹកនាំ កាលហ្នឹងដឹកនាំជ្រើសរើកងទ័ពដើម្បី កាលហ្នឹងវៃលន់ នល់ វៃទ័ពលន់ នល់ ។

ដានី ៖ កាលហ្នឹងអើនៅពេលអើអ៊ំចូលកងទ័ពទៅ កងទ័ពអ៊ំ គេហៅកងទ័ពអីទៅ ហើយនៅកន្លែងណាដែរទៅ?

អឿន ៖ កងទ័ពកាលខ្ញុំចូលហ្នឹងកាលដំបូងកង.«ក» រួចពីហ្នឹងបានម៉ា ម៉ាខេត្តកំពតហ្នឹង បានតែម៉ាកងហ្នឹងទេ ម៉ាកងអនុសេនាធំរួចមកបំបែកបំបែកបំបែកបានច្រើនអញ្ចឹងទៅបានជាកងវរៈសេនាតូចឆ្នាំ៧១-៧២ហ្នឹងពូណា ។

ដានី ៖ អញ្ចឹងពីឆ្នាំ៧០ហ្នឹងមានតែម៉ាកងអនុសេនាធំទេ?

អឿន ៖ បាទ ។

ដានី ៖ ពីរណាធ្វើប្រធានកាលហ្នឹង?

អឿន ៖ អើ ឈ្មោះ ចន ចន អើយស្លាប់ហើយ ។

ដានី ៖ ស្លាប់ហើយ!ដល់ពេលឆ្នាំ៧១-៧២ហ្នឹងយើងបានម៉ាវរៈសេនាតូច?

អឿន ៖ បាទ!បានម៉ាវរៈសេនាតូច ។

ដានី ៖ វរៈសេនាតូចគ្នាប៉ុន្មាននាក់ទៅ?

អឿន ៖ ម៉ាវរៈសេនាតូចហ្នឹងអើពាកង កងអនុសេនាធំអើយចឹងហើយ ពាកងរយ ។

ដានី ៖ ពាកងរយ?

អឿន ៖ បាទ!ពាកងរយ ។

ដានី ៖ ៣០០នាក់?

អឿន ៖ ៣០០នាក់ ម៉ាកងវរៈសេនាតូច ។

ដានី : ដំបូងអនុវរៈសេនាធំ ឆ្នាំ៧១-៧២ មាំវរៈសេនាតូច?

អឿន : បាទ ។

ដានី : ហ្នឹង ចន ហ្នឹងធ្វើប្រធានដដែល?

អឿន : បាទ!ប្រធាន ។

ដានី : ហើយយើងនៅកន្លែងណាខ្លះទៅ យើងកាលហ្នឹង?

អឿន : ខ្ញុំនៅតែម្តុំទូកមាស ស្ទឹងកំពង់ត្រាច មាំផ្លូវខាងលិចកំពតហ្នឹង ហើយដំបូងខាងជើងសមុទ្រ ហ្នឹងការពារខាងជើងសមុទ្រហ្នឹង ។

ដានី : នៅធ្វើអីខ្លះនៅម្តុំហ្នឹងគេធ្វើអីទៅ?

អឿន : កងទ័ព ពួ កាន់អាវុធជាប់ហ៉ាង ។

ដានី : កាលហ្នឹងអើយ យើងឆ្នាំ៧១-៧២ហ្នឹងដូចថាយើងធ្វើកងទ័ពហ្នឹងយើង វៃជាមួយលន់ នល់ឬវៃជាមួយខាងណា?

អឿន : វៃលន់ នល់ ។

ដានី : វៃ លន់ នល់?

អឿន : បាទ!កាលហ្នឹងនៅ វៃ ជាមួយលន់ នល់នៅឡើយ ។

ដានី : ចុះតាកង ចាបតា ប៊ិតហ្នឹងគាត់?

អឿន : កាលជំនាន់ហ្នឹងគាត់ក៏វៃលន់ នល់ដែរគាត់ ។

ដានី : គាត់ធ្វើកងទ័ពដែរឬក៏នៅអើ?

អឿន : គាត់នៅតំបន់ ។

ដានី : គាត់នៅតំបន់?

អឿន : បាទ ។

ដានី : គាត់ជាគណៈតំបន់កាលហ្នឹង?

អឿន : បាទ ។

ដានី : គណៈតំបន់អីដែរទៅកាលហ្នឹង?

អឿន : តំបន់កំពត ។

ដានី : គាត់ជាគណៈតំបន់កំពត ។

អឿន : បាទ ។

ដានី : ពីណាគេប្រធាន?

អឿន ៖ ប្រធានតាចាប និងតាកងចាប ។

ដានី ៖ តាចាបធ្វើប្រធាន?

អឿន ៖ បាទ ។

ដានី ៖ ចុះអើតាប៊ិត?

អឿន ៖ តាប៊ិតគាត់ខាងអនុប្រធាន ។

ដានី ៖ អនុប្រធាន?

អឿន ៖ បាទ!អនុប្រធានផងខាងនគរបាលផង ។

ដានី ៖ ខាងនគរបាលខុសពីយោធាកាលហ្នឹង?

អឿន ៖ បាទ!គាត់រស់ត្រួតលើនគរបាលហ្នឹងទៀត ព្រោះគ្នាគាត់ហ្នឹង៣នាក់២នាក់ ម្នាក់ទៀតឈ្មោះអីទេភ្លេចអស់ហើយ តែកងចាបហ្នឹងគាត់ជាប្រធាន ហើយតាប៊ិតហ្នឹងគាត់ជាអនុប្រធាន ប៉ុនគាត់អត់មានកាន់នៅក្នុងនគរបាលទេណា គាត់គ្រាន់តែត្រួតពិនិត្យទៅលើផ្នែកកងទ័ព និងផ្នែកយោធានៅលើគាត់ទាំងអស់ ។

ដានី ៖ ចុះអ៊ំ ពីឆ្នាំ៧១-៧២ ដែលវរៈសេនា អ៊ំមាននាទីធ្វើអីដែរកាលហ្នឹង?

អឿន ៖ កាលហ្នឹង ខ្ញុំកាលហ្នឹងមេកង កងហា ។

ដានី ៖ មេកង?

អឿន ៖ កងហា ។

ដានី ៖ អនុសេនាតូច?

អឿន ៖ អើ អនុសេនាតូច ។

ដានី ៖ អញ្ចឹងអើ?

អឿន ៖ កាន់បីក្រុមកាលហ្នឹង ។

ដានី ៖ កាន់បីក្រុម?

អឿន ៖ បាទ ។

ដានី ៖ ដល់ពេលបន្ទាប់ពី៧២មកធ្វើអីទៀតទៅ?

អឿន ៖ បន្ទាប់ពីហ្នឹងទៀតមកអនុសេនាធំ ។

ដានី ៖ អនុសេនាធំ?

អឿន ៖ បាទ!អនុសេនាធំម៉ាកងវរយ ។

ដានី ៖ ម៉ាកងវរយ?

អឿន ៖ បាទ! ទៅកាន់បឹកងហា ។

ដានី ៖ ចុះកងទ័ព អ៊ំ ដែលនៅធ្វើការនៅកន្លែងណាខ្លះទៅបន្ទាប់ពីឆ្នាំ៧២មក?

អឿន ៖ អត់ទេពូ! កងទ័ពដើរធ្វើតែម៉ាម៉ុំម៉ាទ្រូវទូកមាស ព្រែកទន្លេអីចឹងមកតាមដើង សមុទ្រម៉ាចប់ចឹងមកតាមដើងកំពត បាទ! អត់មានទៅវៃអីណា១ អត់ទេដែលទៅទេ ។

ដានី ៖ អត់ដែលទៅវៃទេ?

អឿន ៖ បាទ១ អត់ទេ កងហ្នឹងគេហៅថាកងរក្សាការពារជុំវិញកំពតហ្នឹង ។

ដានី ៖ គេហៅកងអី?

អឿន ៖ គេហៅថាកងអើកងពិសេសគេសម្រាប់ការពារនៅហ្នឹងហ្នង អត់ទៅវៃនៅណាទេ ការពារដើងទឹកហ្នង ការពារខាង១ ។

ដានី ៖ ចុះអើនៅហ្នឹងរហូតដល់បែកឆ្នាំ៧៥ ឬក៏មានការផ្លាស់ប្តូរអីទៀតដែរអត់?

អឿន ៖ បែកហ្នឹងមកអើ មុខដំណែង ។

ដានី ៖ អត់ទេអ៊ំ និយាយថា?

អឿន ៖ បែកចេញពីហ្នឹងមក ចូលដល់ឆ្នាំ២០០០ អុះអត់ទេឆ្នាំ៧៨ឬ៧៩ ឬ៧៥ហ្នឹងចូលដល់កន្លែង វៃយួនហើយឆ្នាំ៧៥-៧៦ហ្នឹង ហ្នឹងហើយ ។

ដានី ៖ កាលហ្នឹងពី ៧៣-៧៤ ហ្នឹង អើវរៈសេនាតូចហ្នឹងមានឡើងទៅជាវរៈសេនាធំ ឬកងពលទៀតឬក៏អត់ទេ?

អឿន ៖ នៅកងវរៈសេនាតូច ឡើងដល់វរៈសេនាតូច ប៉ុនតែក្នុងហ្នឹងអើ រួមម៉ាខេត្តកំពតហ្នឹងនិយាយទៅឆ្នាំហ្នឹងម៉ាកងវរៈសេនាធំ ។

ដានី ៖ អញ្ចឹងដល់ពេលបែក៧៥មកយ៉ាងម៉េចទៀតទៅបែក៧៥?

អឿន ៖ បែក៧៥មកខ្ញុំដូចជាភ្លេចអស់ទៅហើយ មិនដឹងរត់ទៅណាកាលហ្នឹង ។

ដានី ៖ បែក៧៥មកអើ អ៊ំកាលហ្នឹងយើង អើ?

អឿន ៖ ចូល! ចូលទៅព្រៃវៃ១ នៅក្នុងព្រៃ វៃដេញគ្នាក្នុងព្រៃ ។

ដានី ៖ វៃក្នុងព្រៃ?

អឿន ៖ វៃដេញគ្នានៅក្នុងព្រៃ វៃយួន អើ យួនចូល ។

ដានី ៖ អត់ទេអើ ៧៥ចូលដល់ឈ្នះលន់ នល់បែកទៅណា?

អឿន ៖ អ្ហ៎ា! កាលពីឈ្នះនៅហ្នឹង ។

ដានី ៖ កាលហ្នុងអ៊ំមានតួនាទីអីដែរ?

អឿន ៖ ខ្ញុំធ្វើកងទ័ព ។

ដានី ៖ ធ្វើកងទ័ព

អឿន ៖ បាទ ។

ដានី ៖ តែយើងមានអនុសេនាធំ?

អឿន ៖ កងវរយកាលបែក៧៥ ។

ដានី ៖ នៅវរសេនាតូចទៀតឬឡើងដល់វរសេនាធំ?

អឿន ៖ អត់ទេ អត់ទាន់ដល់ទេ ។

ដានី ៖ អត់ទាន់ដល់ទេ?

អឿន ៖ បាទ!អត់ទាន់ដល់ទេ នៅវរៈសេនាតូចកាលជិនាន់បែកហើយវរៈឡើងជាវរៈសេនាតូច ។

ដានី ៖ កាលហ្នឹងអើវរៈអ៊ំនៅកន្លែងណាដែរ?

អឿន ៖ នៅអើ នៅខាងលិចនៅកែបថ្មីពូ?

ដានី ៖ នៅកែបថ្មី?

អឿន ៖ បាទ!នៅកែបថ្មីខាងលិចកំពតហ្នឹង ។

ដានី ៖ ធ្វើអីដែរនៅហ្នឹង?

អឿន ៖ នៅហ្នឹងការពាសមុទ្រហ្នឹង អ្វីនូវធ្វើស្រែអំបិលខ្វះអីខ្វះ បាទ ។

ដានី ៖ របស់តំបន់កំពត?

អឿន ៖ បាទ ។

ដានី ៖ អញ្ចឹង តាចាបគាត់នៅទៀតឬក៏អត់ទេ?

អឿន ៖ អត់ទេដល់ហ្នឹងគាត់ស្លាប់ ។

ដានី ៖ គាត់ទៅណាដែរបានស្លាប់ហ្នឹង ហើយស្លាប់ពីអង្កាល់?

អឿន ៖ ស្លាប់ហ្នឹងតាំងពីរមុនបែកអាពតគេយកទៅស្លាប់ ។

ដានី ៖ គេយកទៅស្លាប់អ្ហែ?

អឿន ៖ បាទ ។

ដានី ៖ អញ្ចឹងគេយកតាចាបទៅនៅឆ្នាំណា អ៊ំ មានដឹងអ្ហេះ?

អឿន ៖ អត់ដឹងហាង ភ្លេចអស់អ្ហើយអត់ចាំ ។

ដានី ៖ អ៊ំ!អ៊ំស្គាល់តាចាបច្បាស់ដែរ?

អឿន ៖ បាទ!ចាំ ។

ដានី ៖ និយាយស្គាល់តាចាបច្បាស់ដែរ?

អឿន ៖ ច្បាស់ ។

ដានី ៖ តាចាបមានស្រុកកំណើតនៅឯណាដែរអ៊ំ?

អឿន ៖ ស្រុកកំណើតហ្នឹងមិនដឹងនៅណាទេ តាចាបហ្នឹង ។

ដានី ៖ ចុះអើបន្ទាប់ពីតាចាបទៅ ពីណាគេឡើងជំនួសគាត់?

អឿន ៖ ជំនួសហ្នឹង ឡើងនៅក្នុងកំពតហ្នឹងតាប៊ិត ។

ដានី ៖ តាប៊ិតហ្នឹងជាអ្នកឡើងជំនួសតាចាប?

អឿន ៖ បាទ! ឡើងជំនួសតាចាប ។

ដានី ៖ តំបន់ហ្នឹងតំបន់៣៥ឬតំបន់ណា?

អឿន ៖ តំបន់៣៥ ។

ដានី ៖ ចុះបន្ទាប់ពីតាប៊ិតពីណាទៀតគតពេលដែលអើតាចាបគេដកទៅអើតាប៊ិតឡើងជំនួស?

អឿន ៖ អស់ហើយអត់មានពីណាទៀតទេ រហូតដល់គាត់នៅអង្គាដល់បែកគ្នាអស់តែម្តង ។

ដានី ៖ ចុះអើកងទ័ពរបស់អ៊ំនឹងតាប៊ិតហ្នឹង តាប៊ិតមានប្រាប់យើងឲ្យធ្វើការងារអី ដូចថាតាឌិតគាត់អ្នកបញ្ជាឲ្យធ្វើ?

អឿន ៖ អត់ទេ បន្ទាប់ពីនោះមកគាត់ដាក់ផែនាការឲ្យការពារហ្នឹង ការពារហ្នឹង វៃចុះវៃឡើង ចេញចូលនៅតែហ្នឹង ។

ដានី ៖ អត់មានទៅណាទេ?

អឿន ៖ អត់ទេ! អត់ទៅណាទេ រហូតដល់ ។

ដានី ៖ អ៊ំ នៅកងវរយរហូតដែរ?

អឿន ៖ នៅកងវរយ ។

ដានី ៖ អត់មានផ្លាស់ចេញពីកងទ័ពទេ?

អឿន ៖ អត់ទេ! អត់មានផ្លាស់ទេដល់មកផ្ទះហ្នុង ។

ដានី ៖ ដល់មកផ្ទះ?

អឿន ៖ បាទ ។

ដានី ៖ ចុះតាម៉ុក ដែលឃើញតាម៉ុក?

អឿន ៖ អត់ទេ! អត់ដែលជួប ។

ដានី ៖ អត់ដែលជួបតាម៉ុកទេ?

អឿន ៖ បាទ!អត់ដែលជួបសោះហ្នឹង ។

ដានី ៖ ចុះតំបន់កំពតហ្នឹងជាតំបន់របស់ភូមិភាគណា?

អឿន ៖ អើ ភូមិភាគនារិតី ។

ដានី ៖ ភូមិភាគនារិតី?

អឿន ៖ ភាគច្រើន ពូភ្លេច វាភ្លេចអស់ហើយ ប្រវត្តិតំបន់រស់នៅជំនាន់ប៉ុលពតហ្នឹងអើ វាភ្លេចអស់ហើយ ។

ដានី ៖ ចុះអ៊ំ កាលពីនៅកំពតអីហ្នឹងទាក់ទងហ្នឹងការពារដើងទឹកអីទាក់ទងហ្នឹងកងទ័ពដើងទឹក ការពារដើងទឹកខាងកំពត់សោមអីដែរ?

អឿន ៖ ខាងហ្នឹង បាទ!ទាក់ទង ។

ដានី ៖ ទាក់ទងជាមួយពីណាគេ?

អឿន ៖ ទាក់ទងមួយអើ ខាងអើនេះ អើតាអីនៅវត្តចក លួន ។

ដានី ៖ តាលួន?

អឿន ៖ បាទ!តាលួន ។

ដានី ៖ តាលួន គាត់ធ្វើខាងអី?

អឿន ៖ គាត់ខាងបញ្ជាការដើងទឹក ។

ដានី ៖ បញ្ជាការដើងទឹក ឈ្មោះ តាលួន?

អ្នកជិតខាង ៖ ឥឡូវគាត់ធ្វើក្រុមប្រឹក្សាឃុំ.ខាង ។

ដានី ៖ ចុះអ៊ំស្គាល់ឈ្មោះតាមុតទេ?

អឿន ៖ តាមុត!តាមុតក៏អត់ លឺតែឈ្មោះ ។

ដានី ៖ លឺតែឈ្មោះទេតែអត់ដែលស្គាល់?

អឿន ៖ បាទ!លឺតែឈ្មោះទេ អត់ដែលស្គាល់ ។

ដានី ៖ លឺតែឈ្មោះ លឺតែឈ្មោះកាលហ្នឹងដឹងថាគាត់ធ្វើអី?

អឿន ៖ តាមុតហ្នឹងគាត់ខាងស្អីទេ ខាងនេះខាងអភិបាលស្រុក ។

អ្នកជិតខាង៖ តាមុត មាសហ្នឹងដឹបូងគាត់ជាអភិបាលស្រុកជុំគិរី ប៉ុន្តែគាត់មិនមានជាសមាជិកទេ ។

ដានី ៖ ចុះអ៊ំអញ្ជឹងអើអ៊ំនៅកំពតហ្នឹងរហូតដល់បែកកំពតរហូតដល់ជំនាន់៧៩ហ្នឹ?

អឿន ៖ បាទៗ ។

ដានី ៖ ៧៩ហន្នឹម៉េច នៅពេលដែលយួនចូលមក?

អឿន ៖ យួនចូលមកហ្នឹងវៃចុះ វៃឡើងចឹងខ្ញុំទៅឯព្រៃចឹងទៅ វៃចុះវៃឡើងចឹងទៅដល់ពេល នេះ ទាក់ទងគ្នាដល់ពេលទាក់ទងគ្នាចុះមកហ្នឹង ។

ដានី ៖ នៅឆ្នាំ៧៩អ៊ំមកនៅហ្នឹងហ្មង?

អឿន ៖ អើ!ខ្ញុំនៅឯខាងទូកមាស នៅខាងប្រពន្ធ ។

អ្នកជិតខាង ៖ ទើបនឹងមកនៅឯស្រុកនេះដែរហ្នឹង ។

អឿន ៖ បាទ!ទើបមកនៅស្រុកនេះ ។

ដានី ៖ អើ!ខ្ញុំដូចជាអស់សំណួរអីដែលត្រូវសួរនាំអ៊ំទៀតហើយអ៊ំមានសំណួរអ្វីត្រូវបន្ថែមតាម ក្រោយទៀតទេ?

អឿន ៖ ដូចជាអត់មានទេ ព្រោះខ្ញុំវាភ្លេចផងហ្នឹង ។

ដានី ៖ បាទ! អញ្ចឹងខ្ញុំសូមអរគុណ អ៊ំ ច្រើនហើយអ៊ំ?

អឿន ៖ បាទ ។ **ចប់**

**ចប់**